# គោលបំណង និងអត្តសញ្ញាណដ៏ទេវភាពរបស់ខ្ញុំ

១. សូមអានសេចក្តីថ្លែងការណ៍នេះមកពីអែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ដោយរកមើលព្រះរាជបំណងរបស់ព្រះអង្គសង្គ្រោះសម្រាប់អ្នក ៖



ខ្ញុំជឿថា ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទសព្វព្រះទ័យឲ្យអ្នកមើលឃើញ ទទួលអារម្មណ៍ និងដឹងថាទ្រង់ជាកម្លាំងរបស់អ្នក ។ ដោយមានជំនួយរបស់ទ្រង់ នោះនឹងគ្មានដែនកំណត់ចំពោះអ្វីដែលអ្នកអាចសម្រេចបាននោះទេ ។ ដោយមានជំនួយរបស់ទ្រង់ សក្តានុពលរបស់អ្នកគឺគ្មានដែនកំណត់ឡើយ ។ ទ្រង់សព្វព្រះទ័យឲ្យអ្នកមើលឃើញខ្លួនឯងដូចដែលទ្រង់ទតឃើញអ្នក ។ ដែលវាខុសពីគ្នាយ៉ាងខ្លាំងពីរបៀបដែលពិភពលោកមើលឃើញអ្នក ។

ព្រះអង្គសង្គ្រោះបានប្រកាសយ៉ាងច្បាស់លាស់ថា អ្នកគឺជាបុត្រា ឬបុត្រីរបស់ព្រះដ៏មានឥទ្ធិឫទ្ធិ ។ ព្រះវរបិតាសួគ៌របស់អ្នកគឺជាអង្គដ៏រុងរឿងបំផុតក្នុងសកលលោក ពេញដោយសេចក្តីស្រឡាញ់ អំណរ ស្មោះត្រង់ បរិសុទ្ធ ពន្លឺ ព្រះគុណ និងសេចក្តីពិត ។ ហើយថ្ងៃមួយ ទ្រង់សព្វព្រះទ័យឲ្យអ្នកគ្រងមរតកនូវអ្វីៗទាំងអស់ដែលទ្រង់មាន ។ ( ឌៀថើរ អេហ្វ អុជដូហ្វ « ព្រះយេស៊ូវគ្រីស្ទគឺជាកម្លាំងនៃយុវជន » លីអាហូណា ខែវិច្ឆិកា ឆ្នាំ២០២២ ទំព័រ៩–១០ )

សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា ១៤:៧ ដោយរកមើលអ្វីដែលព្រះវរបិតាសួគ៌មានព្រះរាជបំណងចង់ប្រទានឲ្យអ្នក ។

២. សូមអានសេចក្តីថ្លែងការណ៍នេះមកពីស៊ីស្ទើរ មីឆែល ឌី ក្រេហ្គ ក្នុងគណៈប្រធានយុវនារីទូទៅ ដោយរកមើលការប្រឹក្សារបស់គាត់ដល់មនុស្សម្នាក់ដែលសង្ស័យពីតម្លៃនៃព្រះរបស់ពួកគេ ៖



ប្រហែលរឿងដ៏សំខាន់បំផុតសម្រាប់យើងដើម្បីមើលឃើញយ៉ាងច្បាស់គឺថាតើព្រះជានរណាហើយតើយើងជានរណា—ជាបុត្រាបុត្រីនៃព្រះមាតាបិតាសួគ៌ដែលមាន « និស្ស័យនៃព្រះ និងជោគវាសនាដ៏អស់កល្បជានិច្ច » [ បាវចនាយុវនារី នៅលើគេហទំព័រ ChurchofJesusChrist.org ] ។ ចូរសូមដល់ព្រះឲ្យបង្ហាញការពិតទាំងនេះដល់បងប្អូនរួមជាមួយព្រះទ័យរបស់ទ្រង់ចំពោះបងប្អូន ។ ( មីឆែល ឌី ក្រេហ្គ « Eyes to See » *Liahona* ខែវិច្ឆិកា ឆ្នាំ២០២០ ទំព័រ១៥ )

សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា ១៨:១០–១៣ ដោយរកមើលរបៀបដែលព្រះវរបិតាសួគ៌ខ្វល់ខ្វាយចំពោះអ្នក ។

៣. សូមអានសេចក្តីថ្លែងការណ៍នេះមកពីប្រធាន ស៊ូសាន អេច ផតធ័រ ប្រធានអង្គការបឋមសិក្សាទូទៅ ដោយរកមើលមូលហេតុដែលយើងម្នាក់ៗត្រូវដឹងពីរបៀបដែលព្រះវរបិតាសួគ៌ខ្វល់ខ្វាយចំពោះយើង ៖



នៅពេលបងប្អូនដឹង និងយល់យ៉ាងច្បាស់ថាបងប្អូនត្រូវបានស្រឡាញ់យ៉ាងពេញលេញដូចកូនរបស់ព្រះ នោះវាផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាង ។ វាផ្លាស់ប្តូរនូវរបៀបដែលបងប្អូនមានអារម្មណ៍អំពីខ្លួនឯងនៅពេលបងប្អូនធ្វើខុស ។ វាផ្លាស់ប្តូរនូវរបៀបដែលបងប្អូនមានអារម្មណ៍នៅពេលមានរឿងពិបាកផ្សេងៗកើតឡើង ។ វាផ្លាស់ប្តូរនូវទស្សនៈរបស់បងប្អូនចំពោះបញ្ញត្តិទាំងឡាយរបស់ព្រះ ។ វាផ្លាស់ប្តូរនូវទស្សនៈរបស់បងប្អូនអំពីអ្នកដទៃ និងសមត្ថភាពរបស់បងប្អូនដើម្បីធ្វើឲ្យមានភាពផ្លាស់ប្តូរ ។ ( ស៊ូសាន អេច ផតធ័រ « God’s Love: The Most Joyous to the Soul » *Liahona* ខែវិច្ឆិកា ឆ្នាំ២០២១ ទំព័រ៣៣ )

៤. សូមអានសេចក្តីថ្លែងការណ៍នេះមកពីប្រធាន រ័សុល អិម ណិលសុន ដោយរកមើលអ្វីដែលលោកបានបង្រៀនអំពីសេចក្តីសង្ឃឹមរបស់ព្រះវរបិតាសួគ៌ចំពោះយើងម្នាក់ៗ ៖



ផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់បុត្រាបុត្រីរបស់ទ្រង់អនុញ្ញាតឲ្យយើងរស់នៅកន្លែង និងរបៀបដែលទ្រង់រស់នៅ ហើយទីបំផុតនឹងក្លាយកាន់តែដូចទ្រង់ ។ ផែនការរបស់ទ្រង់ពិតជាធ្វើឲ្យពរជ័យដ៏ធំបំផុតនៃភាពអស់កល្បជានិច្ច កើតមានដល់យើង រួមទាំងសក្តានុពលដើម្បីយើងបាន « គ្រងមរតកជាមួយនឹងព្រះគ្រីស្ទ » ផងដែរ [ រ៉ូម ៨:១៧ ] ។ ( រ័សុល អិម ណិលសុន « ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់ យុវមជ្ឈិមវ័យ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ] នៅលើគេហទំព័រ broadcasts.ChurchofJesusChrist.org )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_553-1